ឯកសារជំនួយស្មារតី
រួមគិត រួមធ្វើ រួមទទួលខុសត្រូវ

លេខ ១២
៩១ តុលា ឆ្នាំ ២០១៤

# តើនយោបាយ ជារឿងអាក្រក់ណាស់មែនទេ?



ជាទូទៅផ្នត់គំនិតរបស់ប្រជាពលរដ្ឋ ដែលតែងតែមិនចូលចិត្ត និងស្អប់ខ្ពើមរឿងនយោបាយ មិនមែនកើតមានតែនៅក្នុងប្រទេសកម្ពុជាយើងប៉ុណ្ណោះទេ ពោលគឺកើតមាននៅលើពិភពលោកទាំងអស់ ជាពិសេសគឺនៅបណ្តាប្រទេសដែលក្រីក្រ ដែលប្រជាពលរដ្ឋមិនសូវមានការយល់ដឹង និងគ្មានចំណេះដឹង។ ពួកគេបានចាត់ទុកការងារនយោបាយ ថាជាការបោកប្រាស់ ជាការងារខ្មៅកខ្វក់ និងកាចសាហាវជាទីបំផុត ហើយអ្នកដែលអាចធ្វើនយោបាយបាន លុះត្រាតែអ្នកនោះពូកែខាងបោកប្រាស់ ភូតកុហកជាដើម។ ពាក្យថានយោបាយ គឺជាការបោកប្រាស់ ជាការងារខ្មៅកខ្វក់ ការងារស្មោកគ្រោក នេះបានលេចឮឡើងតាំងពីសម័យយូរលង់ណាស់មកហើយ នៅលើសកលលោកនេះ មិនមែនទើបតែឮនៅក្នុងពេលបច្ចុប្បន្ននេះទេ។ សម្រាប់បរិបទប្រទេសកម្ពុជា ដែលគេមើលឃើញថា ជាប្រទេសដែលកំពុងអភិវឌ្ឍ ហើយធនធានមនុស្សនៅមានកម្រិត ផ្នត់គំនិតប្រជាពលរដ្ឋមួយចំនួនធំ បានឲ្យនិយមន័យនយោបាយ ក្នុងគោលដៅចំអក និងស្អប់ខ្ពើមថាគឺជានយោបោក ហើយថែមទាំងយល់ថានយោបាយគឺជាការងារមួយថោកទាប មិនស្មោះត្រង់ និងពោរពេញដោយល្បិចកលដ៏ខ្មៅងងឹតគ្រប់បែបយ៉ាង ធ្វើដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ក្រុមបក្ខពួករបស់ខ្លួន និងដើម្បីតែអំណាចប៉ុណ្ណោះ។

ប្រជាពលរដ្ឋទាំងនោះយល់ឃើញថា អ្នកដែលចូលខ្លួនប្រឡូកក្នុងឆាកនយោបាយបាន ទាមទារឲ្យមានសមត្ថភាពខាងនិយាយកុហក បំផ្លើសបំភ្លៃការពិត បោកប្រាស់ មិនមែនជាមនុស្សល្អស្មោះត្រង់ សុចរិត ពួកគេយល់ថាសម្រាប់មនុស្សដែលល្អ ដែលត្រឹមត្រូវស្មោះត្រង់ មិនត្រូវប្រឡាក់ប្រឡូកក្នុងរឿងនយោបាយឡើយ ព្រោះបើពាក់ព័ន្ធនឹងរឿងនយោបាយ នោះគឺជាមនុស្សចោលម្សៀត។ ផ្នត់គំនិតបែបនេះ ពួកគេបានប្រាប់ កូនចៅតៗគ្នា មិនឲ្យកូនចូលរួមក្នុងសកម្មភាពនយោបាយ ដោយប្រាប់ថា បើរៀនគិតតែរឿងរៀនទៅ បើធ្វើស្រែឲ្យគិតតែពីរឿងធ្វើស្រែទៅ បើលក់ដូរ គិតតែពីរឿងលក់ដូរដើម្បីបានប្រាក់ចំណេញទៅបានហើយ កុំនាំគ្នាទៅរវល់រឿងនយោបាយ កុំទៅខ្វល់រឿងនយោបាយ ប្រយ័ត្នគុក! ប្រយ័ត្នងាប់! រស់នៅសម្ងំយកតែសុខរៀងៗខ្លួនទៅ អាណាងាប់ៗទៅ!កុំទៅចំណាយពេលឥតប្រយោជន៍ គិតគូរវាច្រើនពេក វាមិនមែនជារឿងរបស់ពួកយើងទេ។ រឿងស្រុកទេស រឿងជាតិអីហ្នឹង មានគេចាត់ចែងហើយ យើងជាប្រជាពលរដ្ឋ មិនចាំបាច់ទៅខ្វល់នឹងអារឿងនយោបាយ ស្អីហ្នឹងនោះទេ។ ម្យ៉ាងវិញទៀត រឿងនយោបាយនេះ មិនល្អសោះឡើយ មិនស្រួលអាចបាត់បង់អាយុជីវិត ផងក៏មានដែរ។ បើដូច្នេះ តើយើងគួរទាត់ចោលរឿងនយោបាយឬ? ហើយថា តើនយោបាយជារឿងខ្មៅកខ្វក់ អាក្រក់ឬយ៉ាងណា?

នយោបាយ គឺជាអ្វីដែលមានជាគំនិត ឬផ្លូវដែលជនទាំងប្រុសស្រីទាំងឡាយ អាចប្រើសម្រាប់ដោះស្រាយបញ្ហា ឬជាវិធីក្នុងការធ្វើឲ្យបានសម្រេចគោលដៅត្រឹម

ត្រូវអ្វីមួយ។ ដូច្នេះ នយោបាយគឺជារបៀប ឬជាសិល្បៈនៃការនាំឲ្យបានសម្រេចគោលដៅ ហើយដែលគោលដៅនោះប្រាសចាកនូវភាពអាត្មានិយម។ ក្នុងន័យនេះ នយោបាយមិនមែនជាមុខរបររកស៊ីនោះទេ ប៉ុន្តែ នយោបាយជាការងារសម្រាប់បុគ្គលដែលមានចិត្តសប្បុរស មានបេះដូងស្មោះត្រង់បរិសុទ្ធ មានទស្សនវិស័យ ហើយធ្វើការងារដើម្បីជួយសង្គ្រោះមនុស្ស និងសង្គមជាតិ។ លើសពីនេះ នយោបាយ គឺជាតម្រូវការរបស់មនុស្ស នយោបាយធ្វើឲ្យមានការឯកភាព ហើយមានតែនយោបាយទេ ដែលជួយមនុស្សឲ្យរស់នៅក្នុងសង្គមបាន គឺគ្មានការធ្វើបុណ្យឯណាដែលល្អប្រសើរថ្លៃថ្លាជាងការធ្វើនយោបាយជួយជាតិនោះទេ។ បើយើងតាមដានស្វែងយល់ និងពិចារណារឿងនយោបាយឲ្យបានច្បាស់ នោះយើងនឹងយល់ថា តាមការពិត មិនមែននយោបាយជាការងារខ្មៅកខ្វក់ទេ តែអ្នកនយោបាយមួយចំនួនឯណោះទេ ដែលបានធ្វើឲ្យនយោបាយក្លាយទៅជាការងារខ្មៅកខ្វក់ដោយសារគំនិតអាក្រក់ អាត្មានិយម យកនយោបាយជាមុខរបររកស៊ី មកចិញ្ចឹមជីវិតខ្លួន និងគ្រួសារខ្លួន។

ដូច្នេះ ក្នុងន័យត្រឹមត្រូវ នយោបាយមិនមែនជាការងារខ្មៅកខ្វក់ នយោបាយមិនមែនជារឿងចោលម្សៀតនោះទេ តែអ្នកនយោបាយដែលមានគំនិតទុច្ចរិតទៅវិញទេ ដែលជាមនុស្សចោលម្សៀត ថោកទាប មារយាទថោក ដែលធ្វើឲ្យនយោបាយក្លាយជារឿងខ្មៅកខ្វក់ នាំឲ្យប្រជាពលរដ្ឋស្អប់ខ្ពើមនយោបាយ។ តើនៅពេលណាទៅ ទើបនយោបាយត្រូវបានពលរដ្ឋឲ្យតម្លៃវិញ? គឺនៅពេលណា ដែលប្រជាពលរដ្ឋមានការយល់ដឹង តាមដានព័ត៌មានសង្គម ឲ្យបានទៀងទាត់ មានចំណេះដឹងអាចធ្វើការវិភាគពិចារណាពីទង្វើរបស់អ្នកនយោបាយ ដែលកំពុងធ្វើសកម្មភាពលើទីលាននយោបាយ ស្គាល់ច្បាស់អំពីអត្ថប្រយោជន៍នៃនយោបាយសម្រាប់ជាតិ និងបានដឹងច្បាស់ថា ការចូលរួមតាមដានសកម្មភាពនយោបាយ ជាកិច្ចការងារមួយចាំបាច់ធំបំផុត និងជាកាតព្វកិច្ចមួយខានមិនបានរបស់ប្រជាពលរដ្ឋគ្រប់ៗរូប។ ក្រៅពីនេះ ការចូលរួមក្នុងនយោបាយជាច់ខាតទាមទារ ឲ្យអ្នកចូលរួមមានសីលធម៌។ បើកាលណាប្រជាពលរដ្ឋមានសីលធម៌ និងការយល់ដឹងខ្ពស់ នោះធ្វើឲ្យឱកាសដែលអ្នកនយោបាយបោកប្រាស់ អាចមកកាន់ការងារប្រទេសជាតិ ស្ទើរតែគ្មាន។ ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងកិច្ចការនយោបាយសំខាន់ណាស់ក្នុងការជ្រើសរើសបានអ្នកនយោបាយដែលមានទេពកោសល្យខ្ពស់ក្នុងការងារនយោបាយ និងជាអ្នកនយោបាយស្មោះត្រង់ មានបេះដូងបរិសុទ្ធហើយនិងជាមនុស្សពោរពេញទៅដោយទស្សនវិស័យ គិតគូរពីវាសនាប្រទេសជាតិជាធំ មិនមែនជាមនុស្សគិតតែពីផលប្រយោជន៍បក្ខពួក និងគ្រួសារខ្លួននោះឡើយ។

ជារួមមក នៅក្នុងសង្គមជាតិមួយ នយោបាយគឺជារឿងដែលសំខាន់បំផុត មិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋ ពីព្រោះរឿងនយោបាយ ជាផ្ទាំងបាយរបស់ប្រជាពលរដ្ឋ ហើយនយោបាយ ក៏ជះឥទ្ធិពលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងវាសនាអនាគតប្រទេសជាតិទាំងមូល។ តួយ៉ាងប្រសិនបើប្រទេសជាតិមួយ មានបញ្ហាជាប់គាំងនយោបាយ មិនអាចដោះស្រាយចេញគេ កុំបាច់និយាយដល់ការអភិវឌ្ឍធ្វើអ្វី។ ព្រោះថាប្រសិនបើនយោបាយជាប់គាំង ជាតិច្របូកច្របល់ អ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសឈប់មករកស៊ី ប្រជាពលរដ្ឋអត់មានការងារធ្វើ បាតុកម្មមានជាហូរហែ អសន្តិសុខសង្គម និងវិបត្តិសេដ្ឋកិច្ចនឹងកើតឡើង ជាតិនឹងត្រូវដល់នូវមហន្តរាយជាក់ជាមិនខាន ម្ល៉ោះហើយប្រជាពលរដ្ឋម្នាក់ៗ ត្រូវតែចូលរួមក្នុងសកម្មភាពនយោបាយ៕

# តើអ្វីជាប្រភពបញ្ហាពិតប្រាកដរបស់ខ្មែរ?

ប្រទេសខ្មែរយើង តែងតែកើតមានបញ្ហាមិនចេះចប់មិនចេះហើយ ចងចាក់ស្រេះស្មើរតែមើលមិនយល់។ នាពេលបច្ចុប្បន្ន យើងកំពុងតែប្រឈមនឹងបញ្ហារាប់មិនអស់ដែលរួមមាន លំហូរនៃជនអន្តោប្រវេសន៍ខុសច្បាប់ ការរំលោភដីធ្លី ការបំពុលបរិស្ថាន ការបំផ្លិចបំផ្លាញព្រៃឈើ ការរំលោភបំពានសិទ្ធិមនុស្ស អសីលធម៌សង្គម អំពើពុករលួយ ភាពគ្មានការងារធ្វើ ទំនិញឡើងថ្លៃជាដើម។ បញ្ហាដែលបានរៀបរាប់ខាងលើ គ្រាន់តែជាមែកជាងខ្លះៗនៃបញ្ហាតែប៉ុណ្ណោះ។ ជាទស្សនៈ មុននឹងយើង ដោះស្រាយបញ្ហាអ្វីមួយយើងត្រូវស្វែងរក ប្រភពនៃបញ្ហា និងធ្វើការស្រាវជ្រាវរកឫសគល់នៃបញ្ហានោះ។ យើងយល់ថា គ្រប់បញ្ហាទាំងអស់ដែលកើតឡើងនៅក្នុងសង្គមខ្មែរ គឺដោយសារតែអំណាចប្រមូលផ្តុំ។ ហើយកាលណាប្រទេសមួយអំណាចប្រមូលផ្តុំហើយ គឺធ្វើឲ្យច្បាប់ធូរលុង។ នៅពេលដែលការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព ភាពអនាធិបតេយ្យ ឥតសណ្តាប់ធ្នាប់ក៏កើតមានពាសពេញប្រទេស។ ច្បាប់សម្រាប់អ្នកធំ អ្នកកាន់អំណាច មានតម្លៃត្រឹមតែជាសីលធម៌ប៉ុណ្ណោះ គេចង់គោរព ឬមិនគោរពច្បាប់ វាអាស្រ័យទៅលើឆន្ទៈរបស់គេ។ ដោយសារអំណាចប្រមូលផ្តុំ រដ្ឋាភិបាលអាចលូកដៃចូលគ្រប់ស្ថាប័នទាំងអស់ ទាំងស្ថាប័នតុលាការ និងស្ថាប័ននីតិបញ្ញត្តិ។ អ្នកដែលរស់ស្រួលក្នុងសង្គមដែលប្រមូលផ្តុំអំណាច គឺមានតែអ្នកមានអំណាចមានលុយមានបក្ខពួកខ្សែខ្នងតែប៉ុណ្ណោះ។ ជាលទ្ធផលអ្នកដែលរងទុក្ខវេទនា គឺគ្មានអ្នកណាក្រៅពីប្រជាពលរដ្ឋដែលទន់ខ្សោយគ្មានលុយ គ្មានអំណាច គ្មានខ្សែឡើយ។ ហើយដោយសារតែភាពល្ងង់ខ្លៅ ប្រជាពលរដ្ឋភាគច្រើនពេញចិត្ត និងដឹងគុណអ្នកដឹកនាំដែលប្រមូលផ្តុំអំណាច ដែលជារឿយៗ នៅពេលដែលគេធ្វើជាជួយដោះស្រាយបញ្ហា តែតាមពិតអ្នកបង្កបញ្ហាជាកូនចៅរបស់បុគ្គលនោះសោះ។

តើអ្វីទៅជាអំណាចប្រមូលផ្តុំ? ហើយតើអំណាចប្រមូលផ្តុំមានលក្ខណៈដូចម្តេច? អំណាចប្រមូលផ្តុំជាប្រព័ន្ធនៃការដឹកនាំរដ្ឋមួយ ដែលអំណាចក្នុងការចាត់ ចែងកិច្ចការប្រទេស ស្ថិតនៅលើកណ្តាប់ដៃរបស់បុគ្គលតែម្នាក់ ឬមនុស្សមួយក្រុមតូច។ រដ្ឋដែលដឹកនាំដោយប្រព័ន្ធប្រមូលផ្តុំអំណាច គឺដឹកនាំបែបបក្ខពួកនិយម គ្រួសារនិយម ពោលគឺបុគ្គលម្នាក់ ឬមួយក្រុមជាអ្នកសម្រេចកិច្ចការទាំងអស់របស់ប្រទេសជាតិ ដើម្បីតែបម្រើផលប្រយោជន៍បុគ្គល តែការអនុវត្តការងារវិញគ្មានប្រសិទ្ធភាព ដោយសារមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ តែងរុញការទទួលខុសត្រូវទៅឲ្យមន្ត្រីនៅថ្នាក់លើ ជាបន្តបន្ទាប់ ពោលគឺឃុំរុញទៅស្រុក ស្រុករុញទៅខេត្ត និងខេត្តរុញទៅថ្នាក់ជាតិដើម្បីបង្ហាញប្រជាពលរដ្ឋថា ខ្លួនមិនមែនជាអ្នកមានកំហុសនោះទេ។ ជាលទ្ធផល គឺការអនុវត្តទម្រង់នៃការដឹកនាំរដ្ឋមួយ ដែលប្រមូលផ្តុំអំណាចប្រទេសងាយប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ដែលអាចនឹងបាត់បង់ទឹកដី ឬធ្វើឲ្យខ្ទេចខ្ទីជាតិដោយមិនចាំបាច់មានបរទេសណាមកឈ្លានពាននោះទេ។ បើតាមអំណះអំណាងខាងលើនេះ តើយើងអាចសន្និដ្ឋានបានថា គ្រប់បញ្ហាទាំងអស់កើតមាននៅក្នុងសង្គមខ្មែរពិតជាបណ្តាលមកពីអំណាចប្រមូលផ្តុំបានទេ? ចម្លើយគឺ ពិតប្រាកដណាស់។ ជាក់ស្តែងកាលពីឆ្នាំ ២០០៧ លោក **លី ក្វាន់យូ** (Lee Kuan Yew) អតីតប្រធានាធិបតីនៃប្រទេសសិង្ហបុរី បានប្រាប់ទូតសហរដ្ឋអាមេរិកថា មិនគួរណា

ឲ្យប្រទេសកម្ពុជាចូលជាសមាជិកអាស៊ាននោះទេ ព្រោះ ប្រទេសកម្ពុជា មិនទាន់មានតម្លៃរមលប្រសើរណាស់ណាទេ ប្រទេសមួយនេះកំពុងតែជាប់ផុងនៅក្នុងវិបត្តិនយោបាយមួយយ៉ាងជ្រៅ ដោយសារតែការដឹកនាំនយោបាយរបស់ប្រទេសមួយនេះ មានការជំពាក់ជំពិននៅក្នុងរឿងអំណាចប្រមូលផ្តុំក្នុងដៃបុគ្គលដែលជាអ្នកដឹកនាំប្រទេស។ ចំណែកអ្នករាយការណ៍ពិសេសនៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំកម្ពុជា លោក **យ៉ាស្ហ ប៉ាល់ ហ្គៃ (Yash Pal Ghai)** ក៏បានអះអាងថា បញ្ហាស្រុកខ្មែរបណ្តាលមកពីអំណាចប្រមូលផ្តុំដែរ។

ជារួមមក ក្នុងស្ថានភាពប្រទេសយើងបច្ចុប្បន្ន គន្លឹះដែលសំខាន់ជាងគេ ដែលយើងត្រូវគាស់ឲ្យរបើកមុនគេនោះ គឺគាស់តំណាងរាស្ត្រឲ្យចេញពីក្រញាំរបស់បក្ស។ ពាក្យថា តំណាងរាស្ត្រ ដែលយើងគ្រប់គ្នាធ្លាប់ហៅពេញៗមាត់នោះ តាមពិតទៅពួកគេជាតំណាងបក្សទេ មិនមែនតំណាងរាស្ត្រទេ។ គេពុំបានធ្វើការបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសនោះទេ ផ្ទុយទៅវិញគេខិតខំយ៉ាងខ្លាំងដើម្បីប្រយោជន៍ផ្ទាល់ខ្លួនគេ បក្សពួករបស់គេ ហើយគេត្រូវការផ្គាប់ផ្គុន អង្វរកប្រជាពលរដ្ឋ តែពេលរដូវកាលបោះឆ្នោតតែប៉ុណ្ណោះ។ ដើម្បីយកតំណាងរាស្ត្រឲ្យមកនៅខាងប្រជាពលរដ្ឋ ត្រូវបោះឆ្នោតចំមុខដើម្បីរើសពួកគេ មិនមែនបោះឆ្នោតឲ្យរូបសញ្ញាបក្សដូចសព្វថ្ងៃនេះឡើយ។ កាលណាអ្នកតំណាង ក្លាយជាតំណាងរបស់ប្រជាពលរដ្ឋពិតប្រាកដពេលនោះអ្វីៗជាបន្ទាប់នឹងរៀបរយ ព្រោះពួកគេធ្វើការបម្រើប្រយោជន៍ប្រជាពលរដ្ឋ គិតរឿងរួម ហើយបក្ស ឬមេបក្សលែងមានឥទ្ធិពលលើពួកគេទៀតហើយ។ ប្រទេសរបស់យើង ទាំងអស់គ្នាសោះ តែបែរជាត្រូវបុគ្គលតែម្នាក់ ឬមនុស្សមួយក្រុមក្តោបក្តាប់ហើយមកគាបម្ចាស់ប្រទេសឯណោះ ជិតដាច់ខ្យល់ទៅវិញ។ នេះមិនមែនគ្រាន់តែជាទុក្ខវេទនា របស់ប្រជាពលរដ្ឋទេ តែវាជាភាពអាម៉ាស់យ៉ាងខ្លាំងក្លា ដែលប្រជាពលរដ្ឋរាប់លាននាក់ ត្រូវបានមនុស្សតែ ២-៣នាក់ដឹកមុខបំពុលបំផ្លាញ បន្លប់បន្លំស្រេចតែនឹងចិត្តរបស់គេ។ ចំពោះមុខបញ្ហានេះ យើងយល់ថា ត្រូវរៀបចំប្រព័ន្ធរដ្ឋបាលសាធារណៈមួយ ដែលមានលក្ខណៈខ្លី ភ្លឺថ្លា សាមញ្ញ និងមានប្រសិទ្ធភាព។ ហើយដើម្បីបានបែបនោះ គឺមានតែមានប្រជាពលរដ្ឋខ្មែរទេ ដែលអាចដោះស្រាយរួច ពោលគឺប្រជាពលរដ្ឋត្រូវចូលរួមក្នុងកិច្ចការនយោបាយ ដោយការយល់ដឹង ជំរុញឲ្យមានយន្តការដើម្បីធ្វើអោយប្រព័ន្ធដឹកនាំមានប្រសិទ្ធភាព ដែលបំបែកការប្រមូលផ្តុំអំណាចរដ្ឋ ពោលគឺអំណាចទាំងបី (អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ) ឯករាជ្យពីគ្នាផង និងដើម្បីជានាតុល្យភាពអំណាច រវាងអំណាចរដ្ឋ និងអំណាចប្រជាពលរដ្ឋផង។ ការបំបែកអំណាចប្រមូលផ្តុំ ជានាឲ្យសិទ្ធិ និងអំណាចធ្លាក់មកក្នុងកណ្តាប់ដៃប្រជាពលរដ្ឋជាអចិន្ត្រៃយ៍ តាមរយៈតំណាងនៅថ្នាក់ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី និងជាតិ។ ហើយរាល់ការសម្រេចទាំងកិច្ចការដឹកនាំរដ្ឋ និងកិច្ចការអភិវឌ្ឍជាតិលើគ្រប់វិស័យ ត្រូវធ្វើឡើងតាមសេចក្តីត្រូវការ និងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ដែលជាម្ចាស់ប្រទេស៕

### ស្វែងយល់បន្ថែម៖

១. វិទ្យុសំបុកឃ្មុំ FM 105 MHz ភ្នំពេញ: ម៉ោង ២ ដល់ម៉ោង ៣ រសៀល
២. គេហទំព័រ: www.camldp.org
៣. Youtube: ខឹម វាសនា ឬ Khem Veasna
៤. Paltalk: Room Koun Khmer និង
៥. សារអេឡិចត្រូនិក: camldp3@gmail.com